


# ភស្តុតាងខាងវិទ្យាសាស្ត្របានអះអាងថាកម្ពុជានៅតែជាប្រទេសសម្បូរសត្វព្រៃនិងជីវសាស្ត្រចម្រុះ

នៅក្នុងរយៈពេលប៉ុន្មានខែនៃដើមឆ្នាំ២០០៧នេះ ភស្តុតាងខាងជីវសាស្ត្រ ដែលសិក្សាដោយបណ្តាអង្គការសត្វព្រៃមួយចំនួនដែលមានមូលដ្ឋាននៅក្នុងប្រទេសកម្ពុជាបានអះអាងថា សត្វព្រៃពូជកម្រដែលជិតផុតពូជ គឺនៅតែមានវត្តមាននៅក្នុងប្រទេសកម្ពុជា ហើយថ្មីៗនេះ អង្គការការពារសត្វព្រៃមួយបានអះអាងពីការសិក្សាលើសត្វដំរីដែលជាសត្វថនិកសត្វដីគោកធំជាងគេ ហើយកំពុងតែរស់នៅក្នុងប្រទេស ។

យោងទៅតាមសេចក្តីរាយការណ៍ព័ត៌មានជាបន្តបន្ទាប់ចាប់តាំងពីដើមឆ្នាំ រហូតមកដល់ពេលនេះ សត្វព្រៃ និងរុក្ខជាតិកម្រមួយចំនួនបានត្រូវគេអះអាងថា កំពុងតែមានវត្តមាននិងកំពុងតែកើនឡើង ។ បណ្តាអង្គការដែលបានអះអាងនោះ មានដូចជាអង្គការមូលនិធិសត្វព្រៃពិភពលោក(World Wild Fund) បានឱ្យដឹងថា យ៉ាងហោចណាស់ក៏មានរុក្ខជាតិ និងសត្វព្រៃពូជកម្រចំនួនបួនប្រភេទដែរ ដែលបានត្រូវគេប្រកាស។ ចំណែកឯអង្គការផ្សេងៗទៀតដូចជាអង្គការសង្គមអភិរក្សសត្វព្រៃ (Wildlife Conservation Society) ក៏បានបង្ហាញពីរបាយការណ៍នៃការកើនឡើងសត្វស្លាបនិងអង្គការសត្វព្រៃ គឺអង្គការ Fauna&Flora ក៏បានបង្ហាញពីការកើនឡើងនូវសត្វក្រពើ ហើយថ្មីៗនេះក៏បានបញ្ជូននូវសំណាកលាមកទៅវិភាគនៅអូស្ត្រាលី ដើម្បីអះអាងពីវត្តមាននៃសត្វដំរីដែលជាថនិកសត្វដ៏ធំជាងគេបំផុតនៅលើដីគោកនៅក្នុងប្រទេសកម្ពុជា ។

លោកតាន់ សេដ្ឋា ប្រធានគម្រោងអភិរក្សសត្វព្រៃនៅក្នុងខេត្តព្រះវិហារ បានអះអាងថា សត្វព្រៃកម្រជាច្រើនបានត្រូវគេរកឃើញ ហើយកំពុងតែបង្កកំណើតនៅក្នុងប្រទេសកម្ពុជា។

អង្គការមូលនិធិសត្វព្រៃពិភពលោក បានអះអាងថា តាំងពីដើមឆ្នាំនៅភាគឦសាននៃប្រទេសកម្ពុជា គេបានរកឃើញមានរុក្ខជាតិកម្រមួយប្រភេទកន្ធាយក្បាលកង្កែប នៅផ្នែកខាងលើនៃទន្លេមេគង្គ រមាំងមួយប្រភេទនៅក្រចេះ និងខ្លារខិន ព្រមទាំងកូនរបស់វានៅតំបន់ការពារស្រែពកទន្លេមេគង្គ។ ចំណែកឯអង្គការសង្គមអភិរក្សសត្វព្រៃបានអះអាងពីការកើនឡើងនៅសត្វត្មាតពីរប្រភេទ និងសត្វក្ងោ ។ រីឯអង្គការ Fauna&Flora បានអះអាងពីការកើនឡើងនូវសត្វក្រពើភ្នំនៅភ្នំក្រវាញនិងកំពុងតែបញ្ជូនសំណាកលាមកចំនួនជិត ៦០០ដុំទៅសិក្សានៅទីក្រុងមែលបិន ប្រទេសអូស្ត្រាលី ដើម្បីវិភាគពីចំនួនពិតប្រាកដដែលកំពុងតែរស់នៅក្នុងប្រទេសកម្ពុជា ។

លោកទុយ សេរីវឌ្ឍនា ប្រធានគម្រោងអភិរក្សសត្វដំរីនៃអង្គការ Fauna&Flora បានអះអាងថា«យើងកំពុងតែរង់ចាំនូវលទ្ធផលនៃការវិភាគលាមកដំរីដែលយើងប្រមូលចំនួន៥២៥ដុំដើម្បីវាយតម្លៃ និងកំណត់ចំនួនដំរីអាស៊ីដែលកំពុងតែតាំងជម្រកនៅក្នុងប្រទេសកម្ពុជា»។


ឧទ្យានុរក្ស កំពុងប្រមូលលាមក

លោកបានបន្តទៀតថា រហូតមកដល់ពេលនេះ យើងគ្រាន់តែអាចវាយតម្លៃបានថា ដំរីនៅក្នុងប្រទេសកម្ពុជាអាចមានចំនួន១៥០ទៅ២៥០ក្បាល ហើយពួកវារស់នៅរាយប៉ាយពេញប្រទេសកម្ពុជា ជាពិសេសនៅតាមតំបន់ភ្នំ ។ ប៉ុន្តែយើងមិនមានភស្តុតាងអះអាងពិតប្រាកដ ដូច្នេះហើយទើបយើងបញ្ជូនសំណាកលាមកដែលយើងប្រមូលពីតំបន់ខុសគ្នា យកទៅវិភាគ DNA ដែលជាវិធីសាស្ត្រវិទ្យាសាស្ត្រមួយសម្រាប់កំណត់ពីកន្លែងរស់នៅ និងចំនួនដំរីនៅកម្ពុជាឱ្យបានច្បាស់លាស់ ។

លោកអះអាងថា«ចំនួនដំរីពី ១៥០ទៅ២៥០ក្បាលនេះ គឺជាការប៉ាន់ប្រមាណត្រាវៗ តែនៅពេលដែលយើងធ្វើពិសោធន៍ DNA រួចហើយនោះ យើងនឹងដឹងពីជម្រក និងការបន្លាស់ទីរបស់វាពិតប្រាកដដែលអាចឱ្យយើងកំណត់ចំនួនបានរឹតតែច្បាស់ទៅទៀត» ។

លោកបានអះអាងថា លាមកទាំងនោះគឺយើងប្រមូលពីកន្លែងដែលដំរីធ្លាប់រស់នៅនៅក្នុងតំបន់ជាច្រើនខុសៗគ្នានៅតាមជួរភ្នំក្រវាញ ពោលគឺតាំងពីខេត្តកំពង់ស្ពឺ កោះកុង ពោធិ៍សាត់ កំពតជាដើម ។

លោកតាន់ សេដ្ឋាបាននិយាយ ថាដំរីគឺគេរកឃើញមានច្រើនកន្លែងណាស់នៅក្នុងប្រទេសកម្ពុជា សូម្បីតែនៅខេត្តព្រះវិហារក្បែរព្រំដែនឡាវក៏មានដានដំរីដែរ តែការមើលបំពាក់នៅក្នុងព្រៃកម្រ និងពិបាកថតរូបភាពវាណាស់ ។

លោកបានអះអាងថា«យើងអាចប៉ាន់ប្រមាណថា នៅខេត្តព្រះវិហារមានដំរីប្រមាណជាពី២០ទៅ៤០ក្បាលតែងតែឆ្លងព្រំដែនកម្ពុជានិងឡាវ ជាពិសេសគឺត្រង់ទន្លេល្ពៅ»។

លោកសេរីវឌ្ឍនា បាននិយាយថា ដំរីដែលកំពុងតែរស់នៅក្នុងប្រទេសកម្ពុជានោះ គឺជាដំរីអាស៊ីដែលមានរូបរាងខុសប្លែកពីដំរីនៅអាហ្វ្រិក ។

លោកបានអះអាងថា ដំរី អាស៊ីគឺមានស្លឹកត្រចៀកតូចជាងដំរី អាហ្វ្រិក ហើយក្បាលរបស់វាទៀតសោតគឺមានព្រែក ។ ចំណែកក្បាលដំរីអាហ្វ្រិកពុំមានព្រែកទេ ។ ចំណែកឯប្រមោយ និងក្រចកជើងរបស់ដំរីទាំងពីរប្រភេទក៏ខុសគ្នាផងដែរ ។

ការរកឃើញនូវវត្តមានសត្វដំរីនៅក្នុងប្រទេសកម្ពុជា ក៏ដូចជាសត្វព្រៃឯទៀត គឺជាមោទនភាពមួយរបស់ប្រទេស និងប្រជាជាតិ ហើយវាក៏ជាប្រភពដែលអាចឱ្យកម្ពុជាយកមកអភិវឌ្ឍន៍វិស័យទេសចរណ៍ផងដែរ ។

លោកសេរីវឌ្ឍនា បាននិយាយថា វត្តមានសត្វព្រៃទាំងអស់នេះ គឺជាភស្តុតាងមួយប្រាប់ពិភពលោកថា កម្ពុជាគឺជាដែនជម្រកសត្វព្រៃមួយនៅលើពិភពលោក ខណៈដែលចំនួនសត្វព្រៃនៅលើពិភពលោកកំពុងតែជិតបាត់បង់។

ពិស្ណុរ

**ក្រោមកិច្ចសហការជាមួយអង្គការ**

The NGO Forum on Cambodia



ដំរីអាស៊ីដែលគេថតបានពីព្រៃនៅកម្ពុជា កន្លងមក


ដំរីអាស៊ីនៅព្រៃនៃប្រទេសកម្ពុជា ដែលគេថតបានតែបន្តិច